# តើយើងអាចរំពឹងអ្វីពីព្រះជាម្ចាស់នៅពេលនេះ ?
# ( តែងសេចក្តី ទី៤ ក្នុងចំណោមមេរៀនទាំង ៧ )

**សេចក្តីពិតខាងវិញ្ញាណ ទី៤៖ ចូររំពឹងថានឹងបានរួមចំណែកជាមួយព្រះគ្រីស្ទ ក្នុងការរងទុក្ខរបស់ទ្រង់។ ចូររំពឹងថានឹងបានរួមចំណែកនៅក្នុងសិរីល្អរបស់ទ្រង់ដែរ។**



នៅទីកន្លែងជាច្រើន នៅជុំវិញពិភពលោក មានគ្រីស្ទបរិស័ទកំពុងរងទុក្ខ ដោយព្រោះសេចក្តីជំនឿរបស់ពួកគេ។ ការរងទុក្ខកើតមានក្នុងរបៀបខុសៗគ្នាជាច្រើន ខ្លះស្រាលខ្លះធ្ងន់ធ្ងរ ចាប់ពីរឿងតូចតាច រហូតដល់រឿងធំដុំ។ វាជាទម្លាប់ទៅហើយ ដែលថាគ្រីស្ទបរិស័ទតែងតែទទួលរងនូវការត្រូវគេបដិសេធ និងការរើសអើងនៅក្នុងសង្គមខ្លះ។ ជួនកាលពួកគេក៏ជាជនរងគ្រោះ ក្នុងការវាយប្រហារធ្ងន់ធ្ងរ ដូចជា ការចោទប្រកាន់ខុស ការស្អប់ខ្ពើម ការប្រឆាំងជំទាស់ ការបំពារបំពានខាងរាងកាយ ហើយពេលខ្លះថែមទាំងត្រូវបានគេសម្លាប់ទៀតផង។ គ្មានអ្នកណាចង់រងទុក្ខដល់ថ្នាក់ហ្នឹងនោះទេ ប៉ុន្តែ មានពេលខ្លះ ការមានចំណែកនៅក្នុងការរងទុក្ខជាមួយព្រះគ្រីស្ទ ត្រូវបានចាត់ទុកថាជាឯកសិទ្ធិ សម្រាប់គ្រីស្ទបរិស័ទ ក្នុងគ្រប់ជំនាន់ទាំងអស់។ ហើយការរងទុក្ខក្លាយជាក្តីរំពឹងទុកមុនទៅហើយ។

ដំណឹងល្អគឺថា ការមានចំណែកក្នុងការរងទុក្ខនៃព្រះគ្រីស្ទ ក៏ជាមាគ៌ាទៅកាន់សិរីល្អ សម្រាប់យើងនៅថ្ងៃខាងមុខផងដែរ។

**សេចក្តីពិតខាងវិញ្ញាណ ទី៤៖** ចូររំពឹងថានឹងបានរួមចំណែកជាមួយព្រះគ្រីស្ទ ក្នុងការរងទុក្ខរបស់ទ្រង់ ហើយ ចូររំពឹងថានឹងបានរួមចំណែកនៅក្នុងសិរីល្អរបស់ទ្រង់ដែរ។ (រ៉ូម ៨:១៤-១៨; ភីលីព ២:៥-៨; លូកា ២២:៤២-៤៤; ហេព្រើរ ៥:៧; ១២:១-២)

*ពួកកូនរបស់ព្រះ មានចំណែកនៅក្នុងការរងទុក្ខ ជាមួយព្រះគ្រីស្ទ*

នៅក្នុងព្រះគម្ពីរ ព្រះទ្រង់មិនដែលបញ្ជាឲ្យយើងត្រូវតែរងទុក្ខ ឬឲ្យមានចំណែកក្នុងការរងទុក្ខជាមួយព្រះគ្រីស្ទទេ។ ក៏ប៉ុន្តែ សាវ័កប៉ុលមានប្រសាសន៍អំពីការរងទុក្ខ ថាជាបទពិសោធន៍ដែលត្រូវរំពឹងទុកជាមុន សម្រាប់អស់អ្នកដែលជាអ្នកស្មោះត្រង់ ដើរតាមព្រះយេស៊ូវ។ ឧទាហរណ៍ នៅក្នុងសំបុត្រផ្ញើជូនពួកជំនុំរ៉ូម លោកប៉ុលថ្លែងថា៖

ហើយអស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ។ . . . បើសិនណាជាកូនព្រះ ហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ។

(រ៉ូម ៨:១៤-១៧)

ហើយ នៅក្នុងសំបុត្រផ្ញើជូនពួកជំនុំភីលីព លោកប៉ុលបង្ហាញតួអង្គព្រះយេស៊ូវ ថាជាគំរូដែលយើងត្រូវត្រាប់តាម។ លោកថ្លែងថា៖

ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង។ ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង។

(ភីលីព ២:៥-៨)

ព្រះទ្រង់មិនបានតម្រូវឲ្យស្វែងរកការឈឺចាប់ទេ ប៉ុន្តែ ព្រះអង្គបានត្រាស់ហៅយើង ឲ្យដើរតាមព្រះយេស៊ូវ។ បើយើងមានសេចក្តីស្មោះត្រង់ចំពោះទ្រង់ នោះការរងទុក្ខនឹងចូលមកដល់យើងដោយខ្លួនឯង។ ហេតុអ្វី? ព្រោះនៅពេលយើងនិយាយថា យល់ព្រម ចំពោះព្រះ នោះនឹងមានតម្លៃត្រូវតែបង់ថ្លៃ។ នៅពេលដែលយើងនិយាយថា ទេ ចំពោះសេចក្តីល្បួង នោះយើងអាចជាត្រូវរស់នៅ ដោយមិនបានបំពេញតាមបំណងប្រាថ្នាផ្ទាល់ខ្លួន ឬក៏មានអារម្មណ៍ថា យើងកំពុងតែបាត់បង់អ្វីមួយ ដែលយើងចង់ធ្វើ ឬចង់ពិសោធ។ នៅពេលដែលយើងជ្រើសរើសយកភាពបរិសុទ្ធ និងសេចក្តីកោតខ្លាចដល់ព្រះ យើងអាចជាត្រូវបានទុកចោល ដោយគ្មានទីពឹង ឬការកម្សាន្តចិត្ត (ក្លែងក្លាយ) ដែលសេចក្តីល្បួងអាចនឹងផ្តល់ឲ្យយើង។ នៅពេលប្តេជ្ញាថ្វាយជីវិតរបស់យើង ដើម្បីបម្រើព្រះគ្រីស្ទ និងដំណឹងល្អ នោះយើងហើយនិងគ្រួសាររបស់យើង តែងតែត្រូវតែធ្វើការលះបង់ថ្វាយទ្រង់។ នៅពេលដែលយើងប្រកាន់ជំនឿរឹងមាំចំពោះព្រះគ្រីស្ទ ក្នុងចំណោមមនុស្សដែលមិនជឿ នោះយើងត្រូវតែទ្រាំទ្រនឹងអំពើអាក្រក់របស់ពួកគេចំពោះយើង និងការបដិសេធ ការរើសអើង ហើយមានអ្វីៗដែលអាក្រក់ៗលើសពីនោះទៅទៀត។



*ព្រះយេស៊ូវលីឈើឆ្កាងទ្រង់ (វិមាន Chartres Cathedral, ប្រទេសបារាំង)*

ព្រះយេស៊ូវបានជ្រាប ពីតម្លៃនៃការប្តេជ្ញាធ្វើតាមបំណងព្រះហឫទ័យ របស់ព្រះច្បាស់ណាស់។ ដូច្នេះ ទ្រង់បានបញ្ជាក់យ៉ាងច្បាស់ ថាតើការធ្វើជាសិស្សរបស់ទ្រង់ មានន័យដូចម្តេច៖

រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។ ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះខ្ញុំ នោះនឹងបានជីវិតវិញ។

(លូកា ៩:២៣-២៤)

យើងមិនអាចដើរតាមព្រះយេស៊ូវ ទៅតាមផ្លូវទៅឯទីក្រុងយេរូសាឡិម ដូចជាពួកសិស្សដំបូងៗរបស់ទ្រង់បានទៅតាមទ្រង់ទេ ហើយក្នុងចំណោមពួកយើង ក៏គ្មានអ្នកម្នាក់អាចស្លាប់នៅលើឈើឆ្កាងជាមួយទ្រង់ដែរ។ ព្រះយេស៊ូវបានទាមទារការនោះពីយើងទេ។ ទ្រង់បានត្រាស់ហៅយើង ឲ្យដើរតាមទ្រង់នៅផ្លូវ ដែលនាំទៅរកជីវិត។ ទ្រង់បានបង្រៀនយើង ឲ្យលះបង់ការប្រកាន់ខ្ជាប់នូវការចង់បម្រើតែខ្លួនឯង ហើយការរស់នៅក្នុងជីវិតតាមផ្លូវរបស់ខ្លួនឯង តែផ្ទុយទៅវិញ យើងត្រូវដាក់ទ្រង់សំខាន់ ក្នុងជីវិតរបស់យើង ព្រមទាំងថ្វាយចិត្តគំនិតរបស់យើង ដើម្បីបម្រើទ្រង់ និងដំណឹងល្អ ដោយទទួលស្គាល់ថា ការរងទុក្ខនឹងចូលមក បន្ទាប់ពីព្រះបានត្រាស់ហៅយើងមកតាមទ្រង់។ នៅក្នុង "ការបាត់" ជីវិតរបស់យើងនេះ នោះយើងនឹងបានជីវិតវិញ។



*ព្រះយេស៊ូវកំពុងអធិស្ឋាន នៅក្នុងសួនច្បារគេតសេម៉ានី (វិមាន Chartres Cathedral, ប្រទេសបារាំង)*

នៅក្នុងសួនច្បារគេតសេម៉ានី ព្រះយេស៊ូវបានអធិស្ឋានថា៖

ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ។ នោះមានទេវតាលេចមកឯទ្រង់អំពីស្ថានសួគ៌ មកចំរើនកំឡាំងថ្វាយ។ ហើយដោយទ្រង់កើតទុក្ខជាខ្លាំង បានជាទ្រង់អធិស្ឋានទទូចរឹតតែខ្លាំងឡើង ...។

(លូកា ២២:៤២-៤៣)

អ្នកនិពន្ធគម្ពីរ ហេព្រើរ បកស្រាយរឿងនេះយ៉ាងដូច្នេះ៖

ហើយកាលទ្រង់គង់នៅក្នុងសាច់ឈាមនៅឡើយ នោះទ្រង់បានពោលពាក្យអធិស្ឋាន និងពាក្យទូលអង្វរ ដោយសំឡេងជាខ្លាំង ទាំងទឹកភ្នែក ដល់ព្រះដែលអាចនឹងប្រោសឲ្យទ្រង់រួចពីស្លាប់ ហើយដោយព្រោះទ្រង់កោតខ្លាច បានជាព្រះព្រមទទួលទ្រង់។

(ហេព្រើរ ៥:៧)

តើនេះមានន័យដូចម្ដេច? ដោយព្រោះតែយើងដឹងថា ព្រះយេស៊ូវបានយាងពីសួនច្បារគេតសេម៉ានី ទៅឯឈើឆ្កាង ក្នុងរវាងតែប៉ុន្មានម៉ោងទៀតប៉ុណ្ណោះ តើព្រះជាម្ចាស់អាចស្ដាប់ឮសេចក្ដីអធិស្ឋានរបស់ព្រះយេស៊ូវ យ៉ាងដូចម្ដេចទៅ? ព្រះអង្គមិនបានជួយដល់ទ្រង់ ឲ្យរួចផុតពីការសុគតទេ ហើយសូម្បីតែការរងទុក្ខឈឺចាប់ នៅលើឈើឆ្កាង ក៏ទ្រង់គេចមិនផុតផង មុនការរស់ពីសុគតឡើងវិញរបស់ទ្រង់។ ព្រះយេស៊ូវ ជាអ្នកដែលមានពេញដោយសេចក្ដីជំនឿ និងស្មោះត្រង់បំផុត ក្នុងចំណោមបណ្ដាមនុស្សទាំងប៉ុន្មាន ដែលធ្លាប់រស់នៅលើផែនដីនេះ ហើយក៏ជាព្រះរាជបុត្រានៃព្រះតែ១ព្រះអង្គយ៉ាងណាក៏ដោយ ក៏ទ្រង់បានលើកលែងពីការរងទុក្ខ និងការស្លាប់ដែរ ទោះបីទ្រង់បានផ្ទេរសេចក្ដីសំណូមរបស់ទ្រង់សូមការប្រោសឲ្យរួច ក្នុងសេចក្ដីអធិស្ឋានក៏ដោយ។ ហេតុអ្វីបានជាទ្រង់ក៏មិនរួចខ្លួនផង?

ទ្រង់មិនសំចៃទុកឡើយ ព្រោះព្រះជាម្ចាស់ឥតមានបំណងព្រះហឫទ័យ ដើម្បីនឹងលើកលែងទ្រង់ ឲ្យរួចពីសេចក្ដីអាក្រក់នោះឡើយ។ ព្រះអង្គជ្រើសរើសដាក់ឲ្យព្រះរាជបុត្រាទ្រង់ត្រូវសុគត ប្រយោជន៍ដើម្បីនឹងជួយសង្គ្រោះដល់មនុស្សលោកទាំងប៉ុន្មាន។ នោះគឺសំខាន់ជាង ការសំចៃទុកព្រះយេស៊ូវ ឲ្យរួចផុតពីការរងទុក្ខ។

ដោយការស្ដាប់បង្គាប់ព្រះវរបិតា ព្រះយេស៊ូវបានទទួលស្គាល់ការពិតនេះ។ ទ្រង់បានចុះចូលចំពោះបំណងព្រះហឫទ័យនៃព្រះ។ ដូច្នេះហើយ "បានជាព្រះទ្រង់ព្រមទទួលស្ដាប់ទ្រង់"។ នៅក្នុងពេលវេលានៃការរងទុក្ខរបស់ទ្រង់ នោះទ្រង់បានទទួលពីព្រះជាម្ចាស់ នូវអ្វីដែលព្រះអង្គត្រូវការដើម្បីបំពេញការត្រាស់ហៅរបស់ទ្រង់។ ការអធិស្ឋានទាំងឈឺចាប់របស់ព្រះយេស៊ូវ មិនមែនឥតប្រយោជន៍ទេ។ ទោះបីជាការអធិស្ឋានរបស់ទ្រង់ ដើម្បីឲ្យរួចផុតពីការរងទុក្ខ មិនទទួលបានចម្លើយពីព្រះក៏ដោយ ក៏ទ្រង់បានទទួលកម្លាំងមកព្រះអង្គ ដើម្បីប្រឈមមុខនឹងការរងទុក្ខនោះ។

### *យើងនឹងមានចំណែកក្នុងសិរីល្អជាមួយទ្រង់*

នៅពេលជីវិតបានកន្លងផុតទៅ ហើយអស់ទាំងការរងទុក្ខរបស់យើងនឹងត្រូវបញ្ចប់ យើងនឹងទទួលមរតកដ៏ពោរពេញមកព្រះជាម្ចាស់ នូវសេចក្ដីសង្គ្រោះជាមួយព្រះគ្រីស្ទ។ អស់ទាំងការដែលយើងដឹងគឺថា យើងជាកូនព្រះ ហើយមានព្រះវិញ្ញាណទ្រង់ដឹកនាំ។ នោះនឹងបានជាពេលវេលាដ៏ពោរពេញដោយសិរីល្អរបស់យើង។

ដូច្នេះហើយបានជាលោកប៉ុល មានប្រសាសន៍ដោយមានទំនុកចិត្តថា៖

ខ្ញុំរាប់អស់ទាំងសេចក្ដីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្ដីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឲ្យយើងរាល់គ្នាឃើញនោះទេ។

(រ៉ូម ៨:១៨)

យើងមិនសក្ដិសមទទួលសិរីល្អនេះទេ ហើយយើងក៏មិនអាចលើសិរីល្អដោយខ្លួនបានដែរ។ ប៉ុន្តែ សិរីល្អលេចមកពីសិរីល្អព្រះ ដែលសម្ដែងឲ្យឃើញនៅក្នុងយើង។ គឺដោយព្រះគុណ ដែលព្រះវរបិតាបានរាប់យើងជាកូនរបស់ព្រះអង្គ។ ទ្រង់បានប្រទានឲ្យយើងមានលទ្ធភាព ក្នុងការដាក់សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ។ ទ្រង់បានធ្វើឲ្យយើងអាចលីឈើឆ្កាខ្លួនរាល់ថ្ងៃ។ ព្រះវិញ្ញាណទ្រង់បានបង្រៀនយើង ប្រទានអំណាចដល់យើង ហើយដឹកនាំយើង។ ហើយ

ដោយសារព្រះគុណទ្រង់ ព្រះអង្គធ្វើឲ្យយើងអាចនិយាយថា បាទ/ចាស ទៅកាន់ព្រះ និងអាចនិយាយថា បាទ/ចាស ទៅកាន់ព្រះយេស៊ូវ ហើយនិងអាចនិយាយថា បាទ/ចាស ទៅកាន់ការមានចំណែកក្នុងការរងទុក្ខ ជាមួយព្រះគ្រីស្ទដារាបមកដល់ពេលនេះ។ ដោយសារការងារនៃព្រះដ៏ពេញដោយសេចក្ដីស្រឡាញ់នៅក្នុងជីវិតយើង ព្រះដ៏ជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ទ្រង់ត្រូវបានលើកតម្កើងក្នុងសិរីល្អ ហើយយើងក៏នឹងទទួលបានសិរីល្អជាមួយទ្រង់ដែរ។ ក្រោយមកទៀត លោកប៉ុលមានប្រសាសន៍ថា៖

ដ្បិតអ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន ឲ្យបានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឲ្យព្រះរាជបុត្រាបានធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន។ ឯពួកអ្នកដែលទ្រង់បានតម្រូវទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ក៏រាប់ទុកជាសុចរិត ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះទ្រង់ក៏បានដំកើងឡើងដែរ។

(រ៉ូម ៨:២៩-៣០)



*មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

នៅបង្អួចកូលាបខាងលិច នៃវិមាន Chartres Cathedral យើងសម្លឹងឡើងលើឃើញរូបព្រះគ្រីស្ទគង់ លើបល្ល័ង្កជំនុំជម្រះ នៅស្ថានសួគ៌។ តើអ្នកឃើញអ្វី? តើព្រះកាយទ្រង់ក្នុងសិរីល្អ មើលទៅមានសភាពដូចម្ដេច? ប្រសិនយើងមើលដោយយកចិត្តទុកដាក់ យើងនឹងឃើញព្រះហស្តទ្រង់ដែលមានស្នាមមុតដែកគោល និងចំហៀងទ្រង់មានស្នាមរបួសធ្លុះធ្លាយ មានទាំងព្រះលោហិតហូរចេញពីរបួសទ្រង់ទាំងអស់។ រឿងខ្លះ យើងអាចយល់បានទាំងស្រុងទេ ព្រះលោហិតដែលព្រះគ្រីស្ទបានបង្ហូរចេញមក ដើម្បីគ្របបាំងអស់ទាំងអំពើបាប របស់មនុស្សលោកទាំងឡាយណាដែលដាក់សេចក្ដីជំនឿដល់ទ្រង់។ យើងសក្ដិសមនឹងត្រូវជាប់មានទោស ប៉ុន្តែ ព្រះអង្គបានអត់បាបឲ្យយើង។ យើងរំពឹងថា នឹងត្រូវរងទណ្ឌកម្ម ប៉ុន្តែ ចៅក្រមនៃយើងបែរជានឹងស្វាគមន៍យើង ក្នុងនាមជាព្រះអង្គសង្គ្រោះ ដែលបានលះបង់ព្រះអង្គកាយ ព្រមទាំងព្រះជន្មទ្រង់ ជំនួសយើងទាំងអស់គ្នា។

សូមសម្លឹងមើលម្តងទៀត ទៅឯបង្គួចកញ្ចក់គ្រីស្តាល់ ក្នុងរូបភាពខាងលើ។ បាតព្រះហស្តរបស់ព្រះយេស៊ូវ បើកចំហ បង្ហាញថា ទ្រង់គង់នៅស្ថានសួគ៌ រង់ចាំទទួលស្វាគមន៍អ្នក។ ស្នាមរបួសទ្រង់ធានាដល់អ្នកថា ទ្រង់បានបង់ថ្លៃនៃអំពើបាបរបស់អ្នកអស់ហើយ។ អ្នកគឺជាកូនស្ងួនភ្ងាជាទីស្រឡាញ់របស់ព្រះវរបិតា។ អ្នកត្រូវបានបំផ្លាស់បំប្រែ ឲ្យបានដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អ្នកពិតជាកូននៃព្រះ ជាអ្នកដែលមានព្រះវិញ្ញាណបរិសុទ្ធទ្រង់កំពុងធ្វើការខាងក្នុងចិត្តអ្នក ហើយក៏បន្តដឹកនាំ តម្រង់ផ្លូវ កម្សាន្តចិត្ត និងចម្រើនកម្លាំងដល់អ្នក អស់ពេញមួយជីវិត។ បន្ទាប់មក ថ្ងៃមួយ នៅពេលដែលអ្នកបានទៅដល់ស្ថានសួគ៌ អ្នកនឹងទទួលចំណែកក្នុងសិរីល្អ ជាមួយព្រះគ្រីស្ទដែរ។

មនុស្សយើង គ្មានអ្នកណាម្នាក់ ចង់រងទុក្ខដោយព្រោះតែជំនឿរបស់ខ្លួនទេ។ ប៉ុន្តែ ប្រសិនបើការដើរតាមព្រះយេស៊ូវដោយស្មោះត្រង់ មានន័យថាជាការមានចំណែកក្នុងការរងទុក្ខ ជាមួយព្រះគ្រីស្ទ តើអ្នកនឹងជ្រើសរើសយ៉ាងម៉េចទៅវិញ? ព្រះយេស៊ូវគឺជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត។ ទ្រង់ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់យើង។ អ្នកនិពន្ធព្រះគម្ពីរហេព្រើរ បានផ្តល់ដំបូន្មានដែលត្រូវនឹងការរងទុក្ខនេះថា៖

ដូច្នេះ ដែលមានស្មរបន្ទាល់១ហ្វូងធំម្ល៉េះ នៅព័ទ្ធជុំវិញយើង នោះត្រូវឲ្យយើងចោលអស់ទាំងបន្ទុក និងអំពើបាប
ដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយត្រូវរត់ក្នុងទីប្រណាំង ដែលនៅមុខយើង ដោយអំណត់
ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង
ទាំងមើលងាយចំពោះសេចក្តីអាម៉ាស់ខ្មាសនោះ ឲ្យតែបានសេចក្តីអំណរដែលនៅចំពោះទ្រង់
រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ។
(ហេព្រើរ ១២:១-២)

សូមព្រះអង្គប្រទានព្រះគុណ និងកម្លាំងដល់អ្នក តាមដែលអ្នកត្រូវការនៅថ្ងៃនេះ ដើម្បីប្រឈមមុខនឹងការភ័យខ្លាច និងការរងទុក្ខលំបាករបស់អ្នក និងដើម្បីបន្តដំណើរនៃសេចក្តីជំនឿ ព្រមទាំងសេចក្តីស្មោះត្រង់របស់អ្នក ហើយដើម្បីបំពេញបំណងព្រះហឫទ័យនៃព្រះ នៅក្នុងជីវិតរបស់អ្នក។

កម្រងសំណេរតែងសេចក្តី "តើយើងអាចរំពឹងអ្វីពីព្រះនៅពេលឥឡូវនេះ?" ត្រូវបានចងក្រងឡើង ដើម្បីជាការឆ្លើយតបទៅកាន់វិបត្តិជាសាកលឆ្នាំ២០២០ នៃជំងឺកូវីដ១៩។ សំណេរនេះផ្តោតលើរបៀបដែលអ្នកជឿអាចទុកចិត្តព្រះខ្លាំងជាងមុន ក្នុងពេលដែលជួបប្រទះនឹងបញ្ហា។ សំណេរតែងសេចក្តីនេះមានពន្យល់បន្ថែម ស្តីពីអនុសាសន៍សម្រាប់ជូនជាការអនុវត្ត ដែលបានផ្តល់ជូន នៅក្នុងជំពូកទីប្រាំបី "ការទុកចិត្តព្រះ" ក្នុងសៀវភៅដែលមានចំណងជើងថា *THE SPIRIT-LED LEADER: NINE LEADERSHIP PRACTICES AND SOUL PRINCIPLES* (HERNDON, VA: ALBAN INSTITUTE, ឆ្នាំ2005), ទំព័រ 184-190.